## ហេតុអ្វីបានជាសំខាន់ដែលត្រូវដឹង អំពីរោគថ្លើមប្រភេទ C?

ជំងឺថ្លើមប្រភេទ C គឺជាមេរោគដែលឆ្លងតាមរយះពីឈាមមនុស្សម្នាក់ទៅឈាមមនុស្សម្នាក់ទៀត។ មនុស្សភាគច្រើនដែលមានជំងឺនេះគឺអាចប្រកបការរស់នៅដូចធម្មតាបាន ក៏ប៉ុន្តែបើមិនបានដឹងមុនថាមានជំងឺនេះឬមិនបានទទួលការព្យាបាលនោះទេ ជំងឺនេះអាចបង្កើតបញ្ហាយ៉ាងធ្ងន់ធ្ងរដល់សុខភាព ហើយជួនកាលអាចគ្រោះថ្នាក់ដល់ជីវិតផង។ រោគថ្លើមប្រភេទ C គឺអាចកើតឡើងទៅលើមនុស្សគ្រប់ឋានះ ហើយអាការរោគនេះមិនបញ្ចេញសញ្ញារោគភ្លាមៗនោះទេ គឺវាស៊ីពេលយូរ។ ក្នុងកំឡុងពេលដែលជនណាបានឆ្លងមេរោគនេះហើយៗ ប្រសិនបើជននោះគ្មានការប្រុងប្រយ័ត្នទុកជាមុនទេ មេរោគនេះនិងរាលដាលយ៉ាងឆាប់រហ័សពីជនមួយទៅជនមួយទៀត។ មានករណីច្រើនដែលមនុស្សយើងអាចឆ្លងរោគថ្លើមប្រភេទ C នេះបាន ហើយករណីខ្លះគឺទាក់ទងទៅការរស់នៅនិងការអនុវត្តន៏តាមក្បួនវប្បធម៏និងប្រពៃណីរបស់គេ។

**តើលោកអ្នកគិតថាលោកអ្នកបានឆ្លងរោគថ្លើមប្រភេទ C នេះឬ?**

**១/ តើលោកអ្នកបានប្រើវិធីព្យាបាលតាមក្បួនពេទ្យនៅក្រៅប្រទេសឬទេ? ឧទាហរណ៏ ការធ្វើធ្មេញ ការចាក់ថ្នាំបង្ការរោគ និងការវះកាត់។**

**២/ តើលោកអ្នកបានបញ្ចូលឈាមនៅក្រៅប្រទេសឬទេ? ឬធ្លាប់បានបញ្ចូលឈាមក្នុងប្រទេសអូស្ត្រាលីមុនឆ្នាំ១៩៩១?**

**៣/ តើលោកអ្នកបានប្រើប្រាស់ម្ជុលសឺរ៉ាំងដែលគេបានប្រើរួចឬ?**

**៤/ តើលោកអ្នកមានសាក់ឬការចោះទម្លុះលើរាងកាយដោយបានប្រើប្រាស់ឧបករណ៏មិនទាន់រម្ងាប់មេរោគឬ?**

**៥/ តើលោកអ្នកបានប្រើប្រាស់ច្រាសដុះធ្មេញ ឡាមកោរពុកមាត់និងកន្ត្រៃកាត់ក្រចករបស់ជនណាម្នាក់ដែលមានប្រឡាក់ឈាមឬទេ?**

ប្រសិនបើលោកអ្នកឆ្លើយស្របទៅនិងសំណួរណាមួយខាងលើនេះ លោកអ្នកប្រហែលបានឆ្លងរោគថ្លើមប្រភេទ C នេះហើយ។ **P.E.A.C.E.** អាចជួយផ្តល់ពត៏មានស្តីពីជំងឺនេះដល់លោកអ្នកបាននិងជួយឧបត្ថមនៃការសំរេចចិត្តធ្វើតេស្ត៏ឈាម រឿងសុខភាព រឿងជីវិតនិងជនជាទីស្រឡាញ់របស់លោកអ្នក។

## តើខ្ញុំអាចរកជំនួយនេះដោយបែបណា?

## សូមទូរស័ព្ទទៅកាន់អង្គការ
**RELATIONSHIPS AUSTRALIA [SA]**
**ទូរស័ព្ទលេខ ៨២៤៥ ៨១០០**

ហើយសុំជួបបុគ្គលិកណាមួយរបស់ P.E.A.C.E. ឬប្រសិនបើលោកអ្នកចង់និយាយជាមួយអ្នកដែលនិយាយភាសាលោកអ្នកនោះ សូមទូរស័ព្ទទៅក្រសួងអ្នកបកប្រែមុនសិន គឺលេខ **១៣១ ៤៥០**

១/ ប្រាប់ថាភាសាខ្មែរ ដែលលោកអ្នកត្រូវការ ហើយរង់ចាំ សូមកុំដាក់ទូរស័ព្ទចុះ។

២/ នៅពេលអ្នកបកប្រែនិយាយជាមួយលោកអ្នកនោះ សូមប្រាប់គាត់ឲ្យទូរស័ព្ទទៅកាន់អង្គការយើង គឺលេខ **៨២៤៥ ៨១០០**

៣/ បន្ទាប់មកលោកអ្នកអាចនិយាយជាមួយយើងជាភាសាខ្មែរដោយមានការជួយពីអ្នកបកប្រែ។

**សូមទាក់ទងលេខ**

**[08] 8245 8100**

RELATIONSHIPS AUSTRALIA [SA]
49a Orsmond Street, Hindmarsh SA 5007

KHMER—UPDATED APRIL 2005

**បំរើការសង្គមពហុវប្បធម៌ទូទាំងរដ្ឋអូស្ត្រាលីខាងត្បូង**

# យើងនឹងនិយាយ អំពីរោគ ថ្លើមប្រភេទ C

## តើ P.E.A.C.E គឺជាអ្វី?

ក្នុងសង្គមរដ្ឋអូស្ត្រាលីខាងត្បូងពោរពេញទៅដោយមនុស្សមានវប្បធម៌ និងភាសាផ្សេងៗ។ **P.E.A.C.E (ភីស)** គឺជាកិច្ចបំរើការសង្គមពហុវប្បធម៌ ដែលផ្តល់ដោយអង្គការ **RELATIONSHIPS AUSTRALIA [SA] ( រេលេសិនស៊ីបអូស្ត្រាលី)**។ **P.E.A.C.E.** គឺជាឈ្មោះអក្សរកាត់ បើអក្សរពេញគឺ ( Personal Education And Community Empowerment ) ដែលមានន័យថា ការអប់រំផ្ទាល់ខ្លួននិងការផ្តល់អំណាចដល់សង្គម។ គោលបំណងគឺជួយផ្គត់ផ្គង់ជនទាំងឡាយ គ្រួសារនានា ព្រមទាំងសហគមន៍ផ្សេងៗឲ្យរស់នៅមានសុខភាពល្អ។

ប្រសិនបើលោកអ្នកជាជនដែលមកពីវប្បធម៌ផ្សេងៗ ហើយត្រូវការជំនួយក្នុងរឿងជីវិត ដូចជាបញ្ហារោគថ្លើមប្រភេទ C នោះ **P.E.A.C.E.** អាចជួយលោកអ្នកបាន។

## កិច្ចបំរើរបស់យើងគឺឥតគិតថ្លៃទេ (គឺហ្វ្រីFREE)

**P.E.A.C.E.** បានទទួលថវិកាពីក្រសួងកិច្ចការបំរើប្រជាជន

(The Department of Human Services)

## តើ P.E.A.C.E. ជានរណា?

### អ្នកអប់រំសហគមន៍

**(នេះគឺឈ្មោះដែលយើងបានដាក់ឲ្យបុគ្គលិករបស់យើង)**

យើងខ្ញុំធ្វើការជាមួយបុគ្គលិកបុរសនិងស្ត្រីមួយចំនួនដែលមកពីសង្គមពហុវប្បធម៌ផ្សេងៗ។ **“អ្នកអប់រំសហគមន៍”** បានទទួលការហ្វឹកហាត់រួចស្រេចដើម្បីជួយដល់ប្រជាជនក្នុងសហគមន៍គេដែលកើតជំងឺថ្លើមប្រភេទ C ឬបញ្ហាទាក់ទងមេរោគនេះ ដោយផ្តល់នូវការផ្គត់ផ្គង់ ពត៏មាននិងការនែនាំទៅរកអ្នកឯកទេសនិងក្រសួងសំខាន់ៗ សំរាប់ជនទាំងឡាយ គ្រួសារនានា និងសហគមន៍ផ្សេងៗ។ **“អ្នកអប់រំសហគមន៍”** ក៏ធ្វើសហការជាមួយអង្គការនិងក្រសួងឯទៀតៗផងដែរ ដើម្បីឲ្យសិទ្ធិរបស់លោកអ្នកក្នុងការទទួលកិច្ចបំរើនេះបានពេញបំណង។

### អ្នកផ្តល់ឱវាទ

បុគ្គលិកខាងផ្តល់ឱវាទយល់ដឹងនូវឥទ្ធិពលនៃជំងឺថ្លើមប្រភេទ C ដែលកើតដល់ពលរដ្ឋមកពីសង្គមផ្សេងៗនេះ។ បុគ្គលិកទាំងនេះអាចជួយរកគោលដៅជូនលោកអ្នកនិងបង្ហាញផ្លូវដើម្បីឲ្យទៅដល់ដំណោះស្រាយ។ លោកអ្នកអាចជ្រើសរើសយកអ្នកផ្តល់ឱវាទមួយណាក៏បាន ដោយមិនបាច់ពឹងពាក់ទៅលើ **“អ្នកអប់រំសហគមន៍”** ។

### អ្នករៀបចំគំរោងកិច្ចអប់រំសហគមន៍

បុគ្គលិកយើងនេះ គឺផ្តល់នូវជំនួយផ្នែកបង្កើតកម្មវិធីបង្ហាត់បង្រៀនសហគមន៍និងធ្វើឲ្យកម្មវិធីទាំងនេះដំណើរការទៅមុខ។

## តើ P.E.A.C.E. អាចជួយលោកអ្នកដោយវិធីណា?

មនុស្សយើងម្នាក់ៗគឺខុសគ្នាហើយភាពត្រូវការជំនួយក៏ខុសៗគ្នាដែរ។ **P.E.A.C.E.** អាចជួយផ្តល់ជាជំនួយដែលនឹងជួយលោកអ្នកឲ្យហ៊ានបរិយាយអំពីរោគថ្លើមប្រភេទ C។

### P.E.A.C.E. អាចផ្តល់កិច្ចបំរើផ្សេងៗដោយឥតគិតថ្លៃដូចជា

- ការជួយដោយមិនគិតលុយហើយលាក់ការសម្ងាត់របស់លោកអ្នកទៀតផង។
- ផ្តល់ជំនួយដល់ជនផ្សេងៗដែលមានជំងឺនេះក្នុងរយះពេលខ្លីឬយូរក៏បាន ហើយបុគ្គលិកយើងមានការពិសោធន៏ច្រើនក្នុងការងារជួយជនដែលមានជំងឺថ្លើមប្រភេទ C នេះតែម្តង។
- ការផ្តល់ពត៏មានហើយជួយផ្គត់ផ្គង់ជនណាដែលមានការបារម្ភចំពោះគ្រួសារឬមិត្តភ័ក្តិក្នុងបញ្ហាទាំងនេះ។
- អាចទៅជួបលោកអ្នកនៅទីណាក៏បានឲ្យតែងាយស្រួលសំរាប់លោកអ្នក។
- ផ្តល់កម្មវិធីអប់រំផ្សេងៗសំរាប់សង្គមជាក្រុមៗ។

អង្គការយើងយល់ដឹងនិងមានការពិសោធន៏ក្នុងបញ្ហាដែលជនទាំងឡាយមកពីសង្គមនិងវប្បធម៌ផ្សេងៗនេះជួបប្រទះ។